រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

026KH01A-01

វត្តមានរបស់ព្រះគ្រីស្ត និងការរីកសាយ
របស់ក្រុមជំនុំ/ព្រះសហគមន៏



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

២៦

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

លោកគ្រូពលៈដែលជាអ្នកផ្សាយដំណឹងល្អ បានទៅលេងផ្ទះលោក ជុន និងនាងចន្ថា ដើម្បីផ្សាយដំណឹងល្អប្រាប់ពួកគាត់...



១២- តើអ្នកណាដែលទទួលខុសត្រូវ ធ្វើកិច្ចការរបស់ព្រះគ្រីស្ត នៅកន្លែងណាមួយ ? អ្នកជឿដែលរស់នៅទីកន្លែងនោះ ឬក៏ត្រូវតែមានគ្រូមកពីកន្លែងផ្សេងមកទទួលខុសត្រូវ ?

កិច្ចការដែលត្រូវអនុវត្ត

សូមធ្វើតាមគំរូរបស់លោកគ្រូពលៈ ។ សូមបង្រៀន និងណែនាំអ្នកជឿថ្មី អោយផ្សាយដំណឹងល្អ ។ បើសិនជាពួកគេរស់នៅកន្លែងមួយដែលមិនទាន់មានក្រុមជំនុំ សូមជួយពួកគេអោយទទួលខុសត្រូវលើកិច្ចការឃ្វាលបន្តិចម្តងៗ ។

៨- តើយើងត្រូវធ្វើអ្វី យោងទៅតាម លូកា ២៤:២៥-៣២ ?

_____

_____

៩- បើយើងប្រតិបត្តិតាមសេចក្តីបង្គាប់ទាំងប៉ុន្មានរបស់ព្រះជា-ម្ចាស់ តើព្រះអង្គសន្យានឹងយើងដូចម្តេចខ្លះ យោងទៅតាមយ៉ូហាន ១៤:១៥-២១ ?

_____

_____

១០- តើព្រះវិញ្ញាណដ៏វិសុទ្ធជួយយើងអោយអាចធ្វើអ្វី យោងទៅតាមកិច្ចការ ១:៨ ?

_____

_____

១១- តើអ្នកជឿសាមញ្ញម្នាក់ ដែលរស់នៅភូមិឆ្ងាយដាច់ស្រយាលមួយ មានព្រះវិញ្ញាណដ៏វិសុទ្ធដូចសាសនទូត ឬ គ្រូគង្វាលពេញសិទ្ធដែរឬទេ ?

_____

ថ្ងៃមួយ ព្រះជាម្ចាស់នឹងធ្វើឲ្យអ្វីៗគ្រប់យ៉ាងក្លាយជាថ្មី ! ព្រះអង្គនឹងជូតទឹកភ្នែកចេញពីភ្នែករបស់អស់អ្នកដែលជឿលើព្រះយេស៊ូ ហើយព្រះអង្គនឹងប្រទានអោយគេមានជីវិតថ្មីជាមួយព្រះអង្គរហូតអស់កល្ប ! សូមអានខគម្ពីរទាំងនេះ នៅក្នុងវិវរណៈ ២១:៣-៨ ។



ប៉ុន្តែ ខទាំងនេះតែងប្រាប់យើងផងដែរថា ពួកអ្នកមិនជឿ ពួកអ្នកប្រព្រឹត្តអំពើគួរស្អប់ខ្ពើម ពួកអ្នកប្រាសចាកសីលធម៌ និង ពួកអ្នកកុហក នឹងទទួលទោសនៅក្នុងបឹងភ្លើង ។

ពិតមែន ! អំពើបាបបំបែកបំបាក់មនុស្សបាបទាំងអស់ចេញពីព្រះជាម្ចាស់ដែលបរិសុទ្ធ ។ អេសាយ ៥៩:២ ក្នុងព្រះគម្ពីរចែងថា៖ “អំពើអាក្រក់របស់អ្នកវាល់គ្នាទេតើ ដែលខ័ណ្ឌអ្នករាល់គ្នាពីព្រះរបស់អ្នកវាល់គ្នា” ។



តើយើងអាចមានជីវិតថ្មីនេះជាមួយព្រះជាម្ចាស់ ដោយរបៀបណា ?

៤- តើយើងដឹងថា ទោះជាព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះយេស៊ូគ្រីស្ត ជាបុគ្គលផ្សេងគ្នាក៏ដោយ ក៏ព្រះអង្គទាំងពីរអង្គជាព្រះជាម្ចាស់តែមួយ ដោយរបៀបណា ? (យ៉ូហាន ១៤:១៦-១៨) ។

_____

_____

៥- តើយើងត្រូវធ្វើអ្វី យោងទៅតាមកិច្ចការ ២:៣៨ ?

_____

_____

៦- តើយើងត្រូវធ្វើអ្វី យោងទៅតាម ១ ថេស្សាឡូនិក ៥:១៧-១៩ ?

_____

_____

៧- តើយើងត្រូវធ្វើអ្វី យោងទៅតាម ១ កូរិនថូស ១០:១៦ ?

_____

_____

© Project WorldReach © SEAN

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- ហេតុអ្វីបានជាព្រះយេស៊ូត្រូវយាងទៅឋានសួគ៌វិញ ? (យ៉ូហាន ១៦:៧) ។

_____

_____

២- តើព្រះយេស៊ូនៅតែគង់នៅក្នុងពិភពលោកឬ ? ដោយរបៀបណា ? (ម៉ាថាយ ២៨:២០ និង យ៉ូហាន ១៤:១៦-១៨) ។

_____

_____

៣- តើយើងដឹងថា ព្រះយេស៊ូនៅតែមានសេចក្តីស្រឡាញ់ដដែល និងនៅតែអត់ទោសអោយមនុស្សគ្រប់គ្នា ដោយរបៀបណា ? (លូកា ២៤:៤៦-៤៩) ។

_____

_____



© Project WorldReach © SEAN

តើការសុគតរបស់ព្រះយេស៊ូសង្គ្រោះយើង ដោយរបៀបណា ?



ខ្ញុំសូមពន្យល់ ដោយឧទាហរណ៍មួយ ។ មនុស្សកាចសាហាវមួយក្រុម បានចាប់ក្មេងម្នាក់ជំរិតយកលុយ ហើយមានបុរសមានចិត្តសប្បុរសម្នាក់បានយកមាស ៥០ តម្លឹង ទៅអោយមនុស្សទុច្ចរិតទាំងនោះ ដើម្បីលោះយកក្មេងនោះមកវិញ ។ យើងទាំងអស់គ្នាសុទ្ធតែដូចជាក្មេងនោះដែរ គឺថាយើងត្រូវជាប់ក្នុងអំពើបាបរបស់យើង ។ ប៉ុន្តែ ព្រះយេស៊ូបានបូជាព្រះជន្មរបស់ព្រះអង្គ ដើម្បីលោះយើងអោយរួចពីបាប ។ សូមអាន ១ ពេត្រុស ១:១៨-១៩ ។

យើងបរាជ័យហើយ ។ មនុស្សនៅក្នុងភូមិជាច្រើនបានទទួលឫទ្ធានុភាពនៃវត្តមានដ៏វិសុទ្ធរបស់ព្រះគ្រីស្ត ។ ចង្រៃមែន ! យើងរត់ហើយ ។



© Project WorldReach © SEAN



មនុស្សរាប់រយនាក់បានកែប្រែចិត្តគំនិត ហើយនិងទទួលជីវិតអស់កល្ប និងអំណររបស់ព្រះគ្រីស្ត ។







© Project WorldReach © SEAN



តើអ្នកចង់អោយព្រះយេស៊ូគង់ជាមួយ ហើយចង់ទទួលសេចក្តីស្រឡាញ់និងការសង្គ្រោះរបស់ព្រះអង្គដែរឬទេ ? បើអ្នកចង់អ្នកអាចធ្វើបានពេលឥឡូវនេះ ។ សូមមើលខគម្ពីរនេះ នៅក្នុងកិច្ចការ ២:៣៨ ។ ព្រះអង្គមានបន្ទូលប្រាប់មនុស្សបាប តាមរយៈលោកពេត្រុសថា៖ “សូមបងប្អូនកែប្រែចិត្តគំនិត ហើយម្នាក់ៗត្រូវទទួលពិធីជ្រមុជទឹក ក្នុងព្រះនាមព្រះយេស៊ូគ្រីស្តទៅ ដើម្បីអោយព្រះជាម្ចាស់លើកលែងទោសបងប្អូនឱ្យរួចពីបាប ហើយបងប្អូននឹងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាអំណោយទានរបស់ព្រះជាម្ចាស់” ។

បងប្អូនអ្នកជឿទាំងអស់ ក៏មានអារម្មណ៍ថា ព្រះគ្រីស្តគង់ជាមួយគេដែរ ។ ជុនបង្រៀន...



ខ្ញុំអាចទ្រាំបានទាំងអស់ ដោយរួមជាមួយព្រះអង្គ ដែលប្រទានកម្លាំងអោយខ្ញុំ (ភីលីព ៤:១៣) ។

ជុនរំជួលចិត្តមែនទែន ពេលឮពាក្យសំដីនេះ ។





ជុនសិក្សាព្រះគម្ពីរ ដើម្បីអាចបង្រៀនអំពីព្រះគ្រីស្ត ។ ពេលគាត់អានទំព័រនិមួយៗ គាត់ដឹងថា ព្រះគ្រីស្តគង់ជាមួយគាត់...





ព្រះបិតា ព្រះយេស៊ូគ្រីស្ត និងព្រះវិញ្ញាណដ៏វិសុទ្ធ ជាបុគ្គលបីអង្គ តែជាព្រះជាម្ចាស់តែមួយប៉ុណ្ណោះ ។ នេះជាអាថ៌កំបាំងនៃព្រះឯកត្រីអង្គដ៏វិសុទ្ធ ។ នៅពេលដែលព្រះយេស៊ូសន្យាថា នឹងគង់ជាមួយយើង គឺព្រះអង្គចង់មានបន្ទូលថា ព្រះអង្គគង់ជាមួយយើងតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ។



© Project WorldReach © SEAN

ជុនបាននៅជាប់ជាមួយព្រះគ្រីស្ត យ៉ាងជិតស្និទ្ធ ដោយការអធិស្ឋាន ។

ការប្រណីសន្ដោស និងការលើកលែងទោសរបស់ខ្ញុំ ល្មមគ្រប់គ្រាន់សំរាប់កូនហើយ ។ កូនមិននៅតែឯងទេ ព្រោះខ្ញុំនៅជាមួយកូនជានិច្ច (២ កូរិនថូស ១២: ៨-៩) ។



ទូលបង្គំនឹងណែនាំអ្នកជឿអោយជួបជុំគ្នាទៀងទាត់ ដើម្បីថ្វាយបង្គំ និង ធ្វើពិធីកាច់នំបុ័ង ។ ទូលបង្គំនឹងធ្វើពិធីជ្រមុជទឹកអោយអ្នក ដែលកែប្រែចិត្តគំនិត ។ ទូលបង្គំនឹងប្រតិបត្តិតាមសេចក្ដីបង្គាប់គ្រប់យ៉ាងរបស់ព្រះអង្គ ដែលមានចែងនៅក្នុងព្រះបន្ទូល ។

យើងនឹងអានយ៉ូហាន ១៤:១៦-១៨, ១៦:៥-៧, ម៉ាថាយ ២៨:២០, កិច្ចការ ១:៨ និងកាឡាទី ៤:៦ ។ ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអោយយើងអាចមានអារម្មណ៍ដឹងថា ព្រះយេស៊ូគ្រីស្តគង់នៅជាមួយយើង ។ មិត្តសំឡាញ់អើយ ! ខ្ញុំសូមជួយអ្នកអោយអាចអធិស្ឋានបាន ។ យើងនឹងទូលសូមអោយព្រះជាម្ចាស់អត់ទោស និងសង្គ្រោះអ្នកទាំងពីរ ។ អ្នកអាចអធិស្ឋានតាមពាក្យខ្ញុំ គឺនិយាយតាមខ្ញុំមួយឃ្លាម្តងៗ ។





ព្រះជាម្ចាស់បានបើកភ្នែកខាងព្រលឹងវិញ្ញាណរបស់ជុន និងប្រពន្ធ
គាត់អោយបានភ្លឺឡើង ។ ពួកគាត់ទាំងពីរនាក់បានទទួលព្រះ-
វិញ្ញាណដ៏វិសុទ្ធ និងទទួលស្គាល់ថា ព្រះយេស៊ូគង់ជាមួយពួកគាត់
ពិតមែន :





នៅថ្ងៃសៅរ៍...



© Project WorldReach © SEAN



បន្ទាប់ពីបានចែកចាយដំណឹងល្អប្រាប់ប្តីប្រពន្ធពីរនាក់នេះ ច្រើនម៉ោងហើយ លោកគ្រូពលៈក៏សូមលាពួកគាត់ទៅវិញ ។ ជុនសួរគាត់ថា÷



នៅពេលដែលលោកគ្រូពលៈ ដើរចេញពីផ្ទះជុន...



ជុនធ្លាក់ទឹកចិត្តណាស់ ក៏សរសេរសំបុត្រទៅលោកគ្រូពលៈ...



លោកគ្រូពលៈ សូមជំរាបសួរក្នុងព្រះគ្រីស្ត ។ សូមលោកគ្រូអញ្ជើញមកវិញ ព្រោះខ្ញុំមិនអាចធ្វើជាគ្រូគង្វាលទេ ហើយប្អូនចាន់ធីកស្រាទៀតហើយ... ។

លោកគ្រូពលៈសរសេរសំបុត្រឆ្លើយតបថា...

ខ្ញុំត្រូវទៅសួរសុខទុក្ខអ្នកផ្សេងទៀត ទើបខ្ញុំមិនអាចមកភូមិរបស់ប្អូនរាល់អាទិត្យ ។ ប្អូនដឹងពីសេចក្តីបង្គាប់របស់ព្រះគ្រីស្តហើយ ដូចនេះ ប្អូនអាចថែរក្សាក្រុមរបស់ប្អូនដោយខ្លួនឯងបានហើយ ។ សមាជិកក្រុម ក៏ត្រូវទទួលខុសត្រូវដែរ ។ ព្រះយេស៊ូគ្រីស្តគង់ជាមួយប្អូនជានិច្ច ដូចជាព្រះអង្គគង់ជាមួយខ្ញុំជានិច្ចដែរ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំអាចទៅជួបប្អូន នៅថ្ងៃសៅរ៍នេះដែរ ។

មួយអាទិត្យក្រោយមក...



ព្រឹកថ្ងៃបន្ទាប់...



ជុនយល់ច្បាស់ថា ពេលនេះគាត់មាននិស្ស័យពីរ...



និស្ស័យពេញដោយអំពើបាបរបស់លោកជុន និងនិស្ស័យថ្មីរបស់គាត់ក្នុងព្រះគ្រីស្ត តែងតែប្រឆាំងគ្នាជានិច្ច (កាឡាទី ៦:៧-៨, ៥:១៩-២៤) ។ និស្ស័យចាស់របស់គាត់ជាប់ទាក់ទងនឹងលោកអាដាម ។ ឯជុនថ្មីជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធវិញ ។ មារសាតាំងកំពុងល្បួងជុនអោយបោះបង់ លែងរស់នៅតាមព្រះ-វិញ្ញាណដ៏វិសុទ្ធទៀត ។

ថ្ងៃអាទិត្យបន្ទាប់ ជុនដឹកនាំពិធីកាច់នំប៉័ង...





ថ្ងៃនោះ ជុនបានទៅផ្សាយដំណឹងល្អ...



© Project WorldReach © SEAN



ពួកចាស់ទុំរបស់ក្រុមជំនុំម្តាយ បានដាក់ដៃលើជុន អធិស្ឋានទូលសូមអោយព្រះជាម្ចាស់ប្រទានអំណោយទានជាព្រះវិញ្ញាណដ៏វិសុទ្ធដល់ជុន ដើម្បីឱ្យគាត់អាចថែរក្សាក្រុមជំនុំតួចនេះបាន (១ ធីម៉ូថេ ៤:១៤) ។



ពេលវេលាចេះតែកន្លងទៅ... លោកគ្រូពលៈបន្តទៅសួរសុខទុក្ខ និងបង្រៀនក្រុមគ្រួសាររបស់ជុន អោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះគ្រីស្តជាប់រហូត ។ ជុនសិក្សាមេរៀនអំពីកិច្ចការឃ្វាលជាមួយលោកគ្រូពលៈ ។



នៅថៃអង្គារ លោកគ្រូពលៈមកម្តងទៀត...



ពេលដែលយើងទទួលពិធីជ្រមុជទឹក គឺយើងបានរួមស្លាប់ជាមួយព្រះអង្គ ។ យើងស្លាប់ពីអំពើបាប ។ យើងក៏ចាប់ផ្តើមមានជីវិតថ្មីអស់កល្ប ដូចដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញដែរ (រ៉ូម ៦:១-៦) ។



ជុនអត់ទោសអោយគេ ។

ពីមុន ខ្ញុំចង់តែសម្លាប់ពួកឯងរាល់គ្នាទេ ! តែឥឡូវ ខ្ញុំលែងមានចិត្តដូចនេះទៀតហើយ ! ផ្ទុយទៅវិញ ខ្ញុំមានចិត្តអាណិតអ្នកទាំងអស់គ្នាណាស់ ! មិនមែនខ្លួនខ្ញុំទេ តែព្រះគ្រីស្តដែលគង់ក្នុងខ្ញុំ ដែលអាណិតអ្នកទាំងអស់គ្នា ។



ប៊ុនភរម្ល៉េះ ! ឯងថាស្រឡាញ់ខ្ញុំ ! តើអ្នកណាជឿឯងនោះ !

ក្រោយដែលជុនសារភាពទៅព្រះជាម្ចាស់ថា ខ្លួនអាក់អន់ចិត្តខឹងនឹងមិត្តរបស់ខ្លួន ហើយនិងរិះគិតពិចារណាពីការសុគតរបស់ព្រះ-គ្រីស្ត តាមរយៈពិធីកាច់នំបុ័ងហើយ ជុនមានអារម្មណ៍ថា ព្រះអង្គមានវត្តមានគង់នៅជាមួយគាត់ជាថ្មីទៀត ។ ការនិមិត្តឃើញខាងព្រលឹងវិញ្ញាណរបស់គាត់ ក៏មានជាថ្មីឡើងវិញដែរ ។





© Project WorldReach © SEAN

ខ្ញុំនឹងអោយព្រះវិញ្ញាណជួយណែនាំកូនអោយអាចនិយាយបាន (កិច្ចការ ១:៨) ។



ព្រះជាម្ចាស់បានបង្ហាញព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គចំពោះយើង គឺព្រះគ្រីស្តបានសោយទីវង្គតសំរាប់យើងក្នុងពេលដែលយើងនៅជាមនុស្សជាប់បាបនៅឡើយ ។

ជុនអធិស្ឋានក្នុងចិត្តថា...

ព្រះបិតាអើយ កូនចង់ដើរតាមព្រះយេស៊ូគ្រីស្ត ក៏ប៉ុន្តែនៅក្នុងចិត្តកូន នៅមានសេចក្តីអាក្រក់នៅឡើយ ។



ខ្ញុំអត់ទោសអោយកូនហើយ ។ ចូរកូនមានអំណរដោយទទួលស្គាល់ជាថ្មីថា ខ្ញុំគង់ជាមួយកូន (យ៉ូហាន ១:៩) ។


មើលហ្ន៎ ! មិត្តភក្តិឯងកំពុងជិះម៉ូតូរបស់ឯងហ្ន៎ ។ វាកំពុងចំអកអោយឯងណា៎ ។ ឯងកំពុងក្តៅចិត្ត ណាស់មែនទេ ? ឯងគ្មានបានការអីទេ ។


ពិធីកាច់នំបុ័ង ជួយយើងអោយយល់ដឹងពីវត្តមានរបស់ ព្រះយេស៊ូគ្រីស្ត មិនមែនដោយសារពីធីកាច់នំបុ័ងមាន អំណាចនោះទេ ប៉ុន្តែ ដោយសារពិធីកាច់នំបុ័ងផ្តល់ ឱកាសអោយយើងរំលឹកពីការសុគតរបស់ព្រះយេស៊ូ អរព្រះគុណ និងពិនិត្យមើលជីវិត និងចិត្តគំនិតរបស់ យើងផ្ទាល់ (លូកា ២២:១៩) ។
ដំបូង យើងនឹងសំរួមចិត្ត អធិស្ឋានក្នុងចិត្ត ។ យើង នឹងពិនិត្យមើលចិត្តគំនិតរបស់យើង និងសារភាពអំពើបាប របស់យើង ។ បន្ទាប់មក យើងអាចចូលរួមធ្វើពិធី កាច់នំបុ័ង ដោយមនសិការជ្រះស្អាត (១ កូរិនថូស ១១:២៨) ។

ថៃអង្គារក្រោយ...





© Project WorldReach © SEAN